

Khmer

# វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា

បណ្ណពត៌មាន ■ ខែកញ្ញា ឆ្នាំ 2003

កាលពីខែមីនា ឆ្នាំ 2001 រដ្ឋាភិបាលបានប្រកាសឲ្យមានផែនការទូលំទូលាយមួយអស់ទឹកប្រាក់ 18 លាន 8 សែនដុល្លារ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន និង ឧក្រិដ្ឋកម្ម នៅក្នុងកាប្រាម៉ាតា។

វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា (Cabramatta Anti-Drug Strategy) មានរួមទាំង:

- អំណាចប៉ូលិសនិងធនធានបន្ថែម ដើម្បីបិទផ្ទះជួញដូរគ្រឿងញៀន និងបំបាត់អ្នកជួញដូរគ្រឿងញៀន និងអ្នកប្រើគ្រឿងញៀន នៅតាមដងផ្លូវ;
- ការព្យាបាលជាចាំបាច់ខានមិនបានសំរាប់អ្នកប្រើគ្រឿងញៀន និងការពង្រីកសេវាកម្មព្យាបាលនិងជួយធ្វើឲ្យអ្នកប្រើគ្រឿងញៀន មានសភាពប្រសើរឡើងវិញ;
- កម្មវិធីក្រុមឃ្លាំមើលក្រុង (CityWatch) ដើម្បីធ្វើឲ្យប៉ូលិសនិងសហគមន៍ក្នុងតំបន់ រួមដៃគ្នាក្នុងការបង្កើតដំណោះស្រាយទៅនឹងឧក្រិដ្ឋកម្មក្នុងតំបន់; ហើយនិង
- ការពង្រីកកម្មវិធីបង្ការនិងធ្វើអន្តរាគមន៍មុនពេលទាំងឡាយ – ដូចជា Gateways (ផ្លូវចេញចូល) និងក្រុមធ្វើការតាមដងផ្លូវកាប្រាម៉ាតា (Cabramatta Street Team) ។

ការបញ្ចេញការផ្តួចផ្តើមទាំងពួងបានចាប់ផ្តើមឡើងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ។ នៅខែមេសា ឆ្នាំ 2002 លោកអភិបាលរដ្ឋ បានធ្វើរបាយការណ៍អំពីការរីកចំរើន ជូនសភា។ លទ្ធផលបានផ្តល់នូវការលើកទឹកចិត្តជាខ្លាំង។

ឥឡូវនេះ រដ្ឋាភិបាល NSW បានផ្តល់ប្រាក់ចំនួន 9 លាន 3 សែនដុល្លារបន្ថែមទៀត ដើម្បីបន្ថែមពេលនៃវិធីសាស្ត្រប្រឆាំងគ្រឿងញៀននេះ ចំនួនពីរឆ្នាំថែមទៀត – រហូតដល់ខែកក្កដា ឆ្នាំ 2007 ។

បណ្ណពត៌មាននេះ ពន្យល់ដោយត្រួសៗនូវការរីកចំរើនបន្ថែមទៀតនៅក្នុងគំនិតផ្តួចផ្តើមវិធីសាស្ត្រប្រឆាំងគ្រឿងញៀន។

## អំណាចនិងធនធានថ្មីសំរាប់ប៉ូលិស

វិធីសាស្ត្រប្រឆាំងគ្រឿងញៀន នៅកាប្រាម៉ាតា បង្កើតឲ្យមានអំណាចថ្មីសំរាប់ប៉ូលិស និងធនធានបន្ថែមសំរាប់ការងារប៉ូលិស។

ចាប់តាំងពីខែមករា ឆ្នាំ 2001 **ប៉ូលិសបានបិទទ្វារផ្ទះជួញដូរគ្រឿងញៀនចំនួន** 203 ។ ផ្ទះ 143 ក្នុងចំណោមផ្ទះទាំងនោះ **បានត្រូវប៉ូលិសបិទទ្វារដោយប្រើច្បាប់ថ្មីសំរាប់ផ្ទះជួញដូរគ្រឿងញៀន** ដែលបានដាក់ឲ្យមានឡើងកាលពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ដោយមានរួមទាំងផ្ទះចំនួន 35 នៅក្នុងកាប្រាម៉ាតា។

ទីបញ្ជាការប្រចាំតំបន់មូលដ្ឋាន (Local Area Command) កាប្រាម៉ាតា បានប្តឹងចោទមនុស្ស 99 នាក់ (បណ្តឹងចោទ 110) នៅក្រោមច្បាប់បរិវេណទីលំនៅជួញដូរគ្រឿងញៀន ចាប់ពីខែកក្កដា ឆ្នាំ 2001 ដល់ថ្ងៃទី 21 ខែឧសភា ឆ្នាំ 2003 ។ ក្នុងចំណោមបណ្តឹងចោទទាំង នេះ:

- បណ្តឹងចោទ 76 ស្ថិតនៅក្នុងកាប្រាម៉ាតា ចំពោះបទស្ថិតនៅក្នុងចូលទៅក្នុង ឬ ចាកចេញពីផ្ទះជួញដូរគ្រឿងញៀន;
- បណ្តឹងចោទ 35 គឺចំពោះការរៀបចំ ធ្វើ ឬ អនុញ្ញាតឲ្យអ្នកដទៃប្រើបរិវេណទីលំនៅធ្វើជាផ្ទះជួញដូរគ្រឿងញៀន។

បញ្ជា"បណ្តេញចេញពីទីកន្លែង"ចំនួន 4 597 បានធ្វើឡើងនៅក្នុងកាប្រាម៉ាតា មកទល់នឹងថ្ងៃទី 31 ខែឧសភា ឆ្នាំ 2003 ។

**ធនធានប៉ូលិស** ត្រូវបានបង្កើនឡើង :

- ទីបញ្ជាការប្រចាំតំបន់មូលដ្ឋានកាប្រាម៉ាតា ត្រូវបានដូរសាជាថ្មីឲ្យទៅជាកំរិតទី 1 នៅក្នុងការទទួលស្គាល់ថា កាប្រាម៉ាតា គឺជាតំបន់ត្រូវការកិច្ចការប៉ូលិសដ៏ស្មុគស្មាញមួយ;
- ស្ថានីយប៉ូលិសថ្មីមួយនៅកាប្រាម៉ាតា អស់ទឹកប្រាក់ 12លាន 7សែន 8ម៉ឺនដុល្លារ កំពុងត្រូវបានស្ថាបនាឡើង ហើយកំណត់ចប់សព្វគ្រប់នៅខែកញ្ញា ឆ្នាំ 2003;
- មានការបង្កើតនិងបំពេញមុខដំណែងថ្មីនៃភ្នាក់ងារស៊ើបអង្កេតគ្រឿងញៀនចំនួន 10 នាក់; និង
- ក្រុមប៉ូលិសជិះកង់ (Bicycle Squad) ដែលឆ្លើយតបយ៉ាងលឿន បានកើនឡើងពី 6 នាក់ទៅ 12 នាក់។

## អ្នកបកប្រែភាសា

ទីបញ្ជាការប្រចាំតំបន់មូលដ្ឋានកាប្រាម៉ាតា ប្រើសេវាបកប្រែភាសានៅនឹងទីកន្លែងដោយផ្ទាល់នៅគ្រប់ពេលម៉ោង ដែលជាសេវារបស់គណៈកម្មការទំនាក់ទំនងសហគមន៍ (Community Relations Commission) ។ ចាប់ពីខែកញ្ញា ឆ្នាំ 2002 ដល់ខែមិថុនា ឆ្នាំ 2003 អ្នកបកប្រែភាសាមានសំរាប់ភាសាចំនួន 13 ។

## ជំនាញការកាន់តែប្រសើរឡើងសំរាប់ប៉ូលិសដែលធ្វើការជាមួយសហគមន៍

ប៉ូលិស NSW បានរៀបចំឲ្យមានវគ្គសិក្សាវិញ្ញាបនបត្រឯកទេសមួយនៅ TAFE សំរាប់ភ្នាក់ងារប៉ូលិសនៃទីបញ្ជាការប្រចាំតំបន់មូលដ្ឋានកាប្រាម៉ាតា។ ចាប់តាំងពីពេលដែលវគ្គសិក្សា"វៀតណាមនៅក្នុងកិច្ចការប៉ូលិស" បានចាប់ផ្តើមនៅខែសីហា ឆ្នាំ 2001 មក ភ្នាក់ងារ 60 នាក់បានបញ្ចប់វគ្គសិក្សានេះ។ វគ្គនេះបង្ហាត់ប៉ូលិសកាប្រាម៉ាតាឲ្យចេះភាសាវៀតណាមចាំបាច់គ្រប់គ្រាន់សំរាប់ការសន្ទនាយ៉ាងសាមញ្ញ និងកត់ត្រារបាយការណ៍ឧក្រិដ្ឋកម្ម។ ភ្នាក់ងារទាំងពួងក៏ទទួលការហ្វឹកហ្វឺនឲ្យយល់ដឹងអំពីវប្បធម៌និងប្រវត្តិសាស្ត្ររបស់វៀតណាម និងរបៀបធ្វើការជាមួយអ្នកបកប្រែភាសាផងដែរ។

លើសពីនោះទៅទៀត បុគ្គលិក 121 នាក់ដែលធ្វើការនៅក្នុងតំបន់កាប្រាម៉ាតា បានបញ្ចប់សព្វគ្រប់នូវវគ្គសិក្សាខ្លីតែមួយលើក អំពីការយល់ដឹងនិងជំនាញការវប្បធម៌។ បុគ្គលិកទាំងនេះមានរួមទាំងប៉ូលិសនៅក្នុងក្រុមជិះកង់និងប៉ូលិសបំពេញកិច្ចការទូទៅ ភ្នាក់ងារស៊ើបអង្កេត បុគ្គលិករដ្ឋបាល សមាជិក Target Action Group (TAG) និងសមាជិកក្រុមតាមដងផ្លូវនៃក្រសួងសេវាសហគមន៍ (Department of Community Services - DoCS) នៅ កាប្រាម៉ាតា។

Produced by the NSW Premier's Department.

ActNow NSW GOVERNMENT AND YOU
Taking a stand against drugs

## ស្ថិតិឧក្រិដ្ឋកម្ម

យោងទៅតាមការិយាល័យស្ថិតិនិងការស្រាវជ្រាវឧក្រិដ្ឋកម្ម NSW (NSW Bureau of Crime Statistics and Research) ប្រភេទឧក្រិដ្ឋកម្មចំនួន 7 បានធ្លាក់ចុះជាខ្លាំងនៅក្នុងកាប្រាម៉ាតា នៅក្នុងពេលពីរឆ្នាំ ទៅទល់នឹងខែធ្នូ ឆ្នាំ 2002 :

- អំពើលួចប្លន់ដោយគ្មានអាវុធ (ធ្លាក់ចុះ 50%)
- អំពើលួចប្លន់ដោយមានកាំភ្លើង (ធ្លាក់ចុះ 58%)
- អំពើលួចប្លន់ដោយមានអាវុធ ក្រៅអំពីកាំភ្លើង (ធ្លាក់ចុះ 63%)
- ការវាយបំបែក និង ចូលទៅក្នុងទីលំនៅ (ធ្លាក់ចុះ 26%)
- ការវាយបំបែក និង ចូលទៅក្នុងទីកន្លែងដែលមិនមែនជាទីលំនៅ (ធ្លាក់ចុះ 39%)
- ចោរកម្មរថយន្ត (ធ្លាក់ចុះ 29%)
- ចោរកម្មពីក្នុងរថយន្ត (ធ្លាក់ចុះ 23%)។

តួលេខកត់ត្រាផ្សេងទៀត ក៏ចង្អុលបង្ហាញនូវការធ្លាក់ចុះលើការប្រើគ្រឿងញៀននៅក្នុងកាប្រាម៉ាតាផងដែរ :

- ចំនួនម្ជុលនិងសឺរាំងដែលបណ្តាអង្គការផ្នែកសាធារណៈប្រគល់ទៅឲ្យអ្នកប្រើគ្រឿងញៀននៅកាប្រាម៉ាតា បានធ្លាក់ចុះពី 110 463 នៅក្នុងអម្លុងពេលខែកក្កដា ទល់នឹងខែធ្នូ ឆ្នាំ 2001 មកនៅត្រឹមចំនួន 42 235 នៅក្នុងអម្លុងពេល 6 ខែ ចាប់ពីថ្ងៃទី 1 ខែមករា ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 ។
- ការហៅរថយន្តពេទ្យទៅជួយអ្នកប្រើគ្រឿងញៀនហួសកំរិត បានធ្លាក់ចុះពីចំនួន 385 ក្នុងអម្លុងពេលខែកក្កដា ទល់នឹងខែធ្នូ ឆ្នាំ 2000 មកនៅត្រឹមចំនួន 24 ក្នុងអម្លុងពេលចាប់ពីថ្ងៃទី 1 ខែមករា ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003; ហើយ
- ចំនួនស្លាប់ទាក់ទងនឹងគ្រឿងញៀន ក៏បានធ្លាក់ចុះផងដែរ ពីចំនួន 24 នៅក្នុងអម្លុងពេលខែកក្កដា ទល់នឹងខែធ្នូ ឆ្នាំ 2000 មកនៅត្រឹមចំនួន 8 នៅក្នុងអម្លុងពេលដូចគ្នានៃឆ្នាំ 2002។

## CityWatch

CityWatch ធ្វើឲ្យប៉ូលិស អាជីវករ និងសហគមន៍ក្នុងតំបន់ ធ្វើការរួមគ្នាដើម្បីបង្កើតការឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មក្នុងតំបន់។ក្រុមប្រឹក្សា CityWatch បានបង្កើតឡើងនៅខែកក្កដា ឆ្នាំ 2001 ហើយជួបប្រជុំរៀងរាល់ពេលពីរខែម្តង។

មេបញ្ជាការប្រចាំតំបន់មូលដ្ឋាន ធ្វើជាប្រធាននៃក្រុមប្រឹក្សានេះ ហើយគណៈកម្មការទំនាក់ទំនងសហគមន៍ រៀបចំនិងផ្តល់ជំនួយចំពោះការងាររបស់ក្រុមប្រឹក្សានេះ។ សមាជិកទាំងឡាយមានរួមទាំងសមាជិកសភាប្រចាំមណ្ឌលកាប្រាម៉ាតា អភិបាលក្រុង Fairfield អ្នកតំណាងទាំងពួងមកពីក្រុមប្រឹក្សាពាណិជ្ជកម្មកាប្រាម៉ាតា និង Canley Vale សមាគមអាជីវកម្មកាប្រាម៉ាតា ក្រុមសហគមន៍ និងទីភ្នាក់ងាររដ្ឋាភិបាល។

វិធីខ្លះដែលក្រុមប្រឹក្សា CityWatch ធ្វើការជាមួយពលរដ្ឋក្នុងតំបន់ ដើម្បីធានាឲ្យមានការផ្លាស់ប្តូរគ្នានូវព័ត៌មាននិងគំនិត រវាងប៉ូលិសនិងសហគមន៍ មានរួមទាំង:

- ព្រឹត្តិប័ត្រព័ត៌មានជាទៀងទាត់
- ការពិភាក្សាអំពីការអប់រំ
- ការស្រង់មតិដោយដើរសាកសួរតាមផ្ទះ
- ការបង្កើតក្រុមទំនាក់ទំនង
- ព័ត៌មាននៅតាមគេហទំព័រអ៊ីនធើរណិតរបស់ CityWatch ។

កាលពីខែមេសា ឆ្នាំ 2003 CityWatch បានទទួលការយល់ព្រមឲ្យធ្វើជាក្រុមសហគមន៍ទទួលខុសត្រូវប៉ូលិស (Police Accountability Community Team - PACT) សំរាប់ទីបញ្ជាការប្រចាំតំបន់មូលដ្ឋានកាប្រាម៉ាតា។

ក្រុមជំនុំសហគមន៍ប៉ូលិស ឆ្នាំ 2003 បានធ្វើឡើងនៅថ្ងៃទី 3 ខែមេសា ហើយបានធ្វើសេចក្តីសំរេចស្នើសុំ ដើម្បីដោះស្រាយបញ្ហាពេស្យាកម្ម ការគ្រប់គ្រងបញ្ហាគ្រឿងញៀន ចោរកម្មនិងលួចប្លន់ ឧក្រិដ្ឋកម្មលាក់ចំពួន សេវាអតិថិជនរបស់ប៉ូលិស និង ការកែលំអរូបភាពនិងដំណើររបស់ទេសចរទៅកាន់កាប្រាម៉ាតា។

ការស្រង់មតិអាជីវកម្ម បន្តធ្វើទៅទៀត ដោយមានការស្រង់មតិពីអាជីវកម្ម 189 នៅក្នុងតំបន់ CBD មកទល់នឹងពេលនេះ។

ព័ត៌មានលំអិតនិងឯកសារបោះផ្សាយបន្ថែម មាននៅតាមគេហទំព័រអ៊ីនធើរណិតរបស់គណៈកម្មការទំនាក់ទំនងសហគមន៍ : www.crc.nsw.gov.au

## ការព្យាបាល (ការព្យាបាលនិងការធ្វើឲ្យប្រសើរឡើងវិញ)

ការធានាឲ្យនៅក្រៅឃុំរបស់ប៉ូលិសលើបញ្ហាគ្រឿងញៀន (Police Drug Bail) និង Magistrates Early Referral into Treatment - MERIT (ការបញ្ជូនមុនពេលដោយចៅក្រម ឲ្យទៅទទួលការព្យាបាល) បាននិងកំពុងធ្វើប្រតិបត្តិការនៅក្នុងកាប្រាម៉ាតាតាំងពីខែកក្កដា ឆ្នាំ 2001 ។ កម្មវិធីទាំងនេះបញ្ជូនជនល្មើស លើបញ្ហាគ្រឿងញៀន ទៅកាន់សេវាព្យាបាលនិងធ្វើឲ្យប្រសើរឡើងវិញ ដើម្បីបង្ការកុំឲ្យមានឧក្រិដ្ឋកម្មវាក់វិននឹងគ្រឿងញៀន ហើយនិងកែលំអសុខភាពនិងសុខុមាលភាពរបស់បុគ្គលរៀងខ្លួន។

- នៅត្រឹមថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 និងប្រតិបត្តិការតាមរយៈតុលាការ Liverpool កម្មវិធី MERIT បានទទួលយកជន ល្មើស 180 នាក់ ដោយមាន 65 នាក់មកពីកាប្រាម៉ាតា។ ជនល្មើស 89 នាក់ បានបញ្ចប់កម្មវិធី MERIT, ដោយមាន 30 នាក់មកពីកាប្រាម៉ាតា។ ជាទីបញ្ចប់ ជនល្មើស 23 នាក់ ស្ថិតនៅក្នុងកម្មវិធីនេះនៅឡើយ ដោយមាន 5 នាក់មកពីកាប្រាម៉ាតា។
- មកទល់នឹងថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 ប៉ូលិសបានចេញបញ្ជាឲ្យជនល្មើស 29 នាក់ ចូលរួមនៅក្នុងការពិនិត្យវាយតម្លៃនិងការព្យាបាលគ្រឿងញៀន ជាលក្ខខណ្ឌនៃការធានាឲ្យនៅក្រៅឃុំ។
- មកទល់នឹងថ្ងៃទី 31 ខែឧសភា ឆ្នាំ 2003 ប៉ូលិសបានផ្តល់ការធានាឲ្យនៅក្រៅឃុំសំរាប់ជនល្មើស 761 នាក់ ដោយដាក់លក្ខខណ្ឌមិនឲ្យវិលទៅកាន់កាប្រាម៉ាតាវិញ។

**សេវាកណ្តាលសំរាប់ពិនិត្យវាយតម្លៃ** ត្រូវបានបង្កើតឡើងដើម្បីសំរបសំរួលការពិនិត្យវាយតម្លៃ និងការបញ្ជូនអ្នកដែលត្រូវការសេវាកម្មព្យាបាលគ្រឿងញៀន។ នៅត្រឹមថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 សេវានេះបានបំពេញការពិនិត្យវាយតម្លៃសរុបចំនួន 62 នាក់ ដោយមាន 25 នាក់ក្នុងចំណោម 29 នាក់ ដែលបញ្ជូនទៅកាន់សេវានេះនៅក្រោមគំរោងឲ្យនៅក្រៅឃុំរបស់ប៉ូលិសលើបញ្ហាគ្រឿងញៀន ហើយ 37 នាក់ ក្នុងចំណោមអ្នកបញ្ជូនទៅចំនួន 50 នាក់ គឺស្ថិតនៅក្រោមច្បាប់ *ជនស្រវឹង (Intoxicated Persons Act)* ។

**សេវាសុខភាពផ្លូវចិត្ត** បានពង្រីកឡើងសំរាប់អតិថិជនដែលមានបញ្ហាគ្រឿងញៀន និង សុខភាពផ្លូវចិត្ត។ ចាប់ពីខែតុលា ឆ្នាំ 2001 ដល់ខែមិថុនា ឆ្នាំ 2003 មានការបញ្ជូនចំនួន 265 ទៅកាន់សេវានេះ ហើយការបញ្ជូននីមួយៗបានទទួលការពិនិត្យវាយតម្លៃ។

មន្ទីរពេទ្យ Liverpool បានបង្កើនសមត្ថភាពបន្ថែមសំរាប់**កន្លែងព្យាបាលគ្រឿងញៀន**ដល់ទៅ 100 ដើម្បីបំពេញតាមសេចក្តីត្រូវការក្នុងតំបន់។ រដ្ឋាភិបាលបន្តធ្វើការជាមួយសាលាក្រុង Fairfield ដើម្បីបង្កើតសេវាថ្មីមួយសំរាប់ព្យាបាលតាមឱសថសាស្ត្រ នៅឯ Wetherill Park ។ សេវាថ្មីនេះនឹងផ្តល់ថ្នាំទៅឲ្យអ្នកត្រូវការដល់ទៅ 300 នាក់។

**Salvation Army's Follow-on Youth Recovery Support Team Fairfield - FYRST (ក្រុមជំនួយតាមពិនិត្យមើលការរើបរើឡើងវិញរបស់យុវជននៅ Fairfield នៃ Salvation Army)** បាននិងកំពុងផ្តល់សេវាថែទាំក្រោយការព្យាបាល ទៅឲ្យជនវ័យក្មេងដែលរើបរើឡើងវិញ ចេញពីការពឹងផ្អែកលើគ្រឿងញៀន ចាប់តាំងពីខែកុម្ភៈ ឆ្នាំ 2001 ។ នៅខែតុលា ឆ្នាំ 2002 FYRST បាន

ទទួលប្រាក់នៅក្រោមវិធីសាស្ត្រប្រឆាំងគ្រឿងញៀន នៅកាប្រាម៉ាតា ដើម្បីឲ្យសេវានេះធ្វើប្រតិបត្តិការតទៅទៀត។ ចាប់ពីខែតុលា ឆ្នាំ 2002 ដល់ដំណាច់ខែមិថុនា ឆ្នាំ 2003 FYRST បានមើលគ្រប់គ្រងករណី នៃអតិថិជន 97 នាក់។

## ទីលំនៅសំរាប់ពេលមានវិបត្តិ

ការផ្តល់ទីលំនៅមានស្ថិរភាព បានជួយបណ្តាជនក្នុងការរក្សាការ សិក្សានិងបន្តការប្រកបការងាររបស់ខ្លួន ហើយជួយធ្វើឲ្យការរស់នៅ របស់អ្នកទាំងនោះមានទិសដៅថ្មីមួយ។

អង្គការទីលំនៅសហគមន៍ Hume (Hume Community Housing) បានទទួលថវិកាពីក្រសួងទីលំនៅ (Department of Housing) ដើម្បីផ្តល់ទីលំនៅបន្ថែមសំរាប់ពេលមានវិបត្តិ - ទីលំនៅ រយៈពេលខ្លីចំនួន 40 និង រយៈពេលយូរចំនួន 10 - នៅក្នុងកាប្រា ម៉ាតា និង តំបន់ជុំវិញ។

ក្រុមយុវជននៃមជ្ឈមណ្ឌលសហគមន៍កាប្រាម៉ាតា (Cabramatta Community Centre's Youth Team) ផ្តល់ប្រាក់ដើម្បីទិញ គ្រឿងតុទូដាក់នៅតាមទីលំនៅទាំងឡាយដែលត្រូវការចាំបាច់ ដោយ ទទួលថវិកាពីក្រសួងសេវាសហគមន៍។ ក្រុមនេះក៏ចាត់ចែងផងដែរនូវ វេនបុគ្គលិកប្រចាំការសំរាប់"ទីលំនៅពេលមានវិបត្តិ"នៃជនស្រវឹង ដែលទទួលថវិកាពីក្រសួងទីលំនៅផងដែរ។ នៅដំណាច់ខែមិថុនា ឆ្នាំ 2003:

- មនុស្ស 42 នាក់ បានទទួលទីលំនៅនៅក្នុងការជួលផ្ទះចំនួន 34 - មនុស្ស 35 នាក់ដែលមានអាយុរវាង 18 និង 42 ឆ្នាំ ហើយនិង កុមារ 7 នាក់;
- មនុស្ស 53 នាក់បានទទួលទីលំនៅកាលពីគ្រាមុន ចាប់ពី 4 អាទិត្យទៅ 9 ខែ; ហើយ
- ការជួលផ្ទះរយៈពេលយូរចំនួន 5 បានចាប់ផ្តើមឡើង។

## ការតភ្ជាប់អ្នកគ្មានទីលំនៅដែលប៉ះពាល់ដោយគ្រឿងញៀននិង សុរា ទៅកាន់សេវាទាំងពួង

*ច្បាប់ជនស្រវឹង ឆ្នាំ 1979 (Intoxicated Persons Act 1979)* អាចឲ្យប៉ូលិសឃុំខ្លួនជនស្រវឹង ដែលរកឃើញនៅក្នុងទីកន្លែង សាធារណៈ ហើយដែលអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯងឬអ្នកដទៃ។ បន្ទាប់មក ប៉ូលិសដោះលែងអ្នកទាំងនោះទៅឲ្យគ្រួសាររបស់គេ ឬ បញ្ជូនអ្នកទាំងនោះទៅកាន់សេវាព្យាបាល សេវាទីលំនៅ ឬសេវាឯ ទៀតដែលមានលក្ខណៈសមស្រប។

ប៉ូលិស ក្រសួងសុខាភិបាល NSW និងក្រសួងសេវាសហគមន៍នៅ ពាសពេញរដ្ឋ NSW កំពុងបង្កើតពិធីការអំពីរបៀបដែលប៉ូលិសបញ្ជូន ជនស្រវឹងទៅកាន់សេវាសមស្របទាំងឡាយ។ ពិធីការក្នុងតំបន់ កាប្រាម៉ាតាអំពីជនស្រវឹង (Cabramatta Intoxicated Persons Local Protocol) បានអនុវត្តឡើងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ដើម្បីឲ្យកើតឡើងព្រមគ្នានឹងវិធីសាស្ត្រប្រឆាំងគ្រឿងញៀន។

មកទល់នឹងថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 :

- មនុស្ស 50 នាក់បានត្រូវបញ្ជូននៅក្រោមពិធីការនេះ ទៅកាន់ សេវាសុខាភិបាល ដើម្បីធ្វើការពិនិត្យវាយតម្លៃជាបន្ទាន់ អំពី លទ្ធភាពគ្រោះថ្នាក់ដល់សុខភាព; ហើយ
- មនុស្ស 32 នាក់ បានទទួលទីលំនៅចំនួន 43 ថ្ងៃ ដែលផ្តល់ឲ្យ ដោយក្រុមធ្វើការតាមដងផ្លូវការប្រាម៉ាតា នៅតាមផ្ទះដែលរៀបចំ ជាពិសេសសំរាប់ការប្រើប្រាស់នៅក្រោមពិធីការនេះ។

## អន្តរាគមន៍ និង វិធានការបង្ការ

ចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ក្រុមធ្វើការតាមដងផ្លូវរបស់ ក្រសួងសេវាសហគមន៍ បានជួយជនវ័យក្មេង ដែលគ្មានទីលំនៅនិង ទទួលផលប៉ះពាល់ដោយគ្រឿងញៀន ក្នុងការស្វែងរកទីលំនៅ និង ទទួលជំនួយពីបណ្តាសេវាព្យាបាលគ្រឿងញៀននិងសុរា។ សេវានេះ មានទីតាំងនៅឯស្ថានីយប៉ូលិសកាប្រាម៉ាតា ហើយធ្វើប្រតិបត្តិការ ជារៀងរាល់ថ្ងៃ។

មកទល់នឹងថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 ក្រុមធ្វើការនៅតាមដងផ្លូវ :

- បានធ្វើការទាក់ទងមនុស្ស 1 136 នាក់ នៅក្នុងពេល 2 660 ដង;
- ទទួលការបញ្ជូនចំនួន 564 ពីប៉ូលិសតំបន់; ហើយ
- ធ្វើការបញ្ជូនចំនួន 1 158 ទៅកាន់បណ្តាសេវាទីលំនៅ គ្រឿង ញៀននិងសុរា ហើយនិងសេវាឯទៀត។

## ការជួយគ្រួសារក្នុងការដោះស្រាយបញ្ហាគ្រឿងញៀនខុសច្បាប់

គំរោងការងារជំហានទៅមុខ របស់ Uniting*Care* Burnside (Uniting*Care* Burnside's *Moving Forward*) ផ្តល់ជំនួយ ល្អិតល្អន់ទៅឲ្យគ្រួសារ ការពិគ្រោះឱវាទផ្នែកគ្រឿងញៀន ការទទួល ការព្យាបាលគ្រឿងញៀន និង សេវាឯទៀតដែលអាចជាការចាំបាច់។ ចាប់ពីពេលចាប់ផ្តើមនៅខែតុលា ឆ្នាំ 2001 ទល់នឹងថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003:

- ពលរដ្ឋ 104 គ្រួសារ បានត្រូវបញ្ជូនទៅកាន់ជំហានទៅមុខ;
- បានផ្តល់ជំនួយទៅកាន់ពលរដ្ឋ 73 គ្រួសារ ដោយជាប់ទាក់ទង នឹងអ្នកប្រើគ្រឿងញៀន 68 នាក់ ជនវ័យក្មេងអាចមានគ្រោះថ្នាក់ 18 នាក់ ហើយនិងមាតាបិតា ក្មេង និងសមាជិកឯទៀតរបស់ គ្រួសារ ដែលមិនប្រើគ្រឿងញៀន ចំនួន 105 នាក់។

ក្រសួងសេវាសហគមន៍ ផ្តល់ប្រាក់សំរាប់គំរោងការងារនេះ។

## ការតភ្ជាប់គ្រួសារជាមួយនឹងសាលារៀននិងសហគមន៍ទាំងពួង

### *កម្មវិធី Gateways*

**កម្មវិធី Gateways** បានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ 2001 នៅក្នុង តំបន់កាប្រាម៉ាតា / Fairfield ។ កម្មវិធីនេះជួយសិស្សសាលាដែល ប្រហែលជាជាប់ទាក់ទងនឹងគ្រឿងញៀន ឬ មិនបញ្ចប់ Year 12 ។

មកទល់នឹងខែមិថុនា ឆ្នាំ 2003 :

- សិស្ស 519 នាក់ បានទទួលការគ្រប់គ្រងករណីរៀងៗខ្លួន;
- សិស្ស 150 នាក់ បានបញ្ចប់វគ្គសិក្សាវិជ្ជាជីវៈ TAFE;
- សិស្ស 96 នាក់ បានបញ្ចប់វគ្គសិក្សាស្វាគមន៍ភ្ញៀវ តាមរយៈកម្មវិធីហាងកាហ្វេ Salvation Army's Café Horizons; ហើយ
- សិស្ស 320 នាក់ មានផែនការសិក្សាអប់រំរៀងៗខ្លួន ដែលត្រូវ បានសរសេរជាលាយលក្ខណ៍អក្សរសំរាប់ខ្លួនគេ។

សាលាមធ្យមសិក្សាទាំងអស់ក្នុង Fairfield កំពុងអនុវត្តផែនការ សកម្មភាព ដើម្បីដោះស្រាយបញ្ហាអប់រំអំពីគ្រឿងញៀន ដែលពាក់ព័ន្ធនឹងសិស្សចាប់ពី Year 7 ដល់ Year 10 ។

### *Schools as Community Centres និង Primary Connect*

សាលារៀនអាចជាកន្លែងសំខាន់មួយសំរាប់លើកកំពស់ចំណងទាក់ ទងល្អប្រសើរ រវាងកុមារជាមួយនឹងជនវ័យក្មេង គ្រួសាររបស់គេ ជាមួយនឹងសហគមន៍ទាំងពួង ដែលខ្លួនរស់នៅ។

**កម្មវិធី Families First 'Schools as Community Centres' (គ្រួសារជាដំបូង "សាលាជាមជ្ឈមណ្ឌលសហគមន៍")** កំពុងជួយគ្រួសារដែលមានកូនអាយុតិចជាង 8 ឆ្នាំ នៅឯសាលា ទាំងឡាយក្នុងតំបន់កាប្រាម៉ាតា, Canley Vale, Bonnyrigg និង Fairfield ។

សាលានីមួយៗនៃសាលាទាំងនេះ មានអ្នកសំរបសំរួលម្នាក់ ដើម្បី ចាត់ចែងកម្មវិធីនោះ។

នៅឯ Fairfield ក្រុមលេង កម្មវិធីរបាំសហគមន៍ និង គំរោង ការងារសិល្បៈសហគមន៍ បានបង្កើតការតភ្ជាប់ល្អប្រសើររវាងផ្ទះ សាលា និង សហគមន៍។ នៅឯកាប្រាម៉ាតា កម្មវិធីនេះបានធ្វើការ ប្រជុំផ្តល់ពត៌មានចំនួន 87 លើក សំរាប់មាតាបិតា ហើយបានធ្វើការ ទាក់ទងចំនួន 1 539 លើកជាមួយគ្រួសារទាំងឡាយ ក្នុងអម្លុងពេល មួយឆ្នាំ។ នៅឯ Canley Vale ការប្រជុំសហគមន៍ សកម្មភាពនៃ

ក្រុមលេង និង ការប្រជុំផ្តល់ព័ត៌មានសំរាប់មាតាបិតា បានផ្តល់គោលការណ៍មួយសំរាប់ការចូលរួមកាន់តែជិតស្និទ្ធរបស់សហគមន៍ នៅក្នុងសាលា។ នៅឯ Bonnyrigg ការតភ្ជាប់ជាមួយនឹងសហគមន៍ជនជាតិដើម បានត្រូវបង្កើតឡើង។

កម្មវិធី *Schools as Community Centres* ត្រូវបានបំពេញបន្ថែមដោយ Primary Connect ។

**Primary Connect** ផ្តល់ជំនួយទៅឲ្យកុមារអាយុ 5-12 ឆ្នាំដែលងាយរងគ្រោះ និងគ្រួសាររបស់កុមារទាំងនេះ ជាពិសេសកុមារដែលអាចមានគ្រោះថ្នាក់ក្នុងការឈប់រៀនមុនពេលធម្មតា ប្រើគ្រឿងញៀន មានឥរិយាបថធ្វើឲ្យអ្នកដទៃអាក់អន់ចិត្ត និងបង្កគ្រោះថ្នាក់ដល់ខ្លួន ឯង។ ការរកមើលដឹងនិងការដោះស្រាយបញ្ហាទាំងពួងនៅមុនពេល នឹងបញ្ឈប់មិនឲ្យក្មេងទាំងនោះទៅជាមានការលំបាកយ៉ាងធ្ងន់ធ្ងរ។

អ្នកសំរបសំរួលនៃ Primary Connect បានធ្វើសហការជាមួយបណ្តាសេវាក្នុងតំបន់ ដូចជាសុខភាពសហគមន៍ Burnside និង Karitane ដើម្បីរៀបចំ :

- ការប្រជុំពិភាក្សាយល់ដឹងមួយអំពីគ្រឿងញៀនសំរាប់មាតាបិតា និងគ្រួសារវៀតណាម ដែលមានការចូលរួមដោយមនុស្ស ប្រហែល 200 នាក់;
- ការប្រជុំពិភាក្សាមួយនៅឯក្លឹបយុវជនសហគមន៍ប៉ូលិសកាប្រាម៉ាតា អំពីការប្រាស្រ័យទាក់ទងរវាងមាតាបិតានិងកូន ក្នុងរង្វង់ខ្លឹមសារនៃគ្រួសារវៀតណាម។

## កម្មវិធីសិក្សាអប់រំពហុវប្បធម៌អំពីគ្រឿងញៀន

ក្រសួងរបស់អភិបាលរដ្ឋ (Premier's Department) បាននិងកំពុងធ្វើការជាមួយក្រុមផ្តល់ឱវាទសហគមន៍ និងទីភ្នាក់ងារក្នុងតំបន់ ដើម្បីបង្កើតកម្មវិធីអប់រំអំពីគ្រឿងញៀន និងពត៌មានសំរាប់គ្រួសារទាំងពួង នៅក្នុងសហគមន៍វៀតណាម ខ្មែរ លាវ និង ចិន។

សហគមន៍នីមួយៗបាននិងកំពុងប្រើប្រាស់វិធីមួយចំនួនដើម្បីឲ្យមានការចូលរួមពីសំណាក់មាតាបិតា ហើយដើម្បីបញ្ជូនពត៌មានឲ្យដល់គោលដៅ - ដូចជាកម្មវិធីវិទ្យុ អត្ថបទសារពត៌មាន ការប្រជុំផ្តល់ពត៌មានសំរាប់មាតាបិតា និង ខ្សែអាត់សម្លេង។

ទូរស័ព្ទផ្តល់ជំនួយសំរាប់សហគមន៍វៀតណាម បានទទួលសំណូមពរជំនួយចំនួន 26 រវាងខែសីហា ឆ្នាំ 2002 និង ខែមេសា ឆ្នាំ 2003 ។ វីដេអូអប់រំមាតាបិតាវៀតណាម ត្រូវបានផលិតឡើងតាមរយៈការទទួលប្រាក់ពីក្រសួងសេវាសហគមន៍ និង ក្រសួងរបស់អភិបាលរដ្ឋ។

បណ្ណាល័យរបស់សាលាក្រុង Fairfield បានបន្ថែមសម្ភារៈឯកសាររបស់ខ្លួន ដើម្បីរួមបញ្ចូលពត៌មានអំពីគ្រឿងញៀននិងសុរា ជាភាសាវៀតណាម ខ្មែរ លាវ និង ចិន។

## វិធានការសេវាឆ្លើយតបកាន់តែប្រសើរ សំរាប់ជនវ័យក្មេង

សាលាក្រុង Fairfield និងក្រសួងរបស់អភិបាលរដ្ឋ បានកោះប្រជុំក្រុមការងារយុវជនមួយ (Youth Action Team) នៃបណ្តាស្ថាប័នផ្តល់សេវារបស់រដ្ឋនិងមិនមែនរបស់រដ្ឋ នៅខែកក្កដា ឆ្នាំ 2001 ។ ក្រុមនេះកំពុងធ្វើការរិះរកវិធីដើម្បី កែលំអការផ្តល់សេវាទៅឲ្យជនវ័យក្មេងនៅក្នុងតំបន់។

ចាប់តាំងពីឆ្នាំ 2002 មក ក្រុមនេះបានធ្វើការរួមគ្នាដើម្បីកែលំអដំណើរការបញ្ជូន និង គ្រប់គ្រងករណី ជំនួយសំរាប់ជនវ័យក្មេង និង ទំនាក់ទំនងប៉ូលិស-យុវជន។

## ការពង្រីកសកម្មភាពបោសសំអាតម្ជុលនិងសឺរ៉ាំងនៅកាប្រាម៉ាតា

ជនល្មើសដែលជាប់ឃុំតាមបញ្ជាឃុំឃាំងតាមរយៈកាល ធ្វើការដើរល្បាតតាមដងផ្លូវនិងទីសាធារណៈ នៅក្នុងសង្កាត់អាជីវកម្មកណ្តាលរបស់កាប្រាម៉ាតា និងតំបន់ជិតខាង ដោយប្រមូលយកសឺរ៉ាំងដែលគេបោះចោល។ នៅក្នុងអម្លុងពេល 2 ឆ្នាំ ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2003 អ្នកជាប់ឃុំតាមរយៈកាលបានរើសសឺរ៉ាំងចំណុះមួយមីលីលីត្រ ចំនួនសរុប 25 277 ។ អ្នកជាប់ឃុំទាំងនេះក៏បានរើសកញ្ចប់បោះចោល សំរាប់ខ្ចប់សឺរ៉ាំងដែរ។

សេវាសំអាតម្ជុល ដែលផ្តល់ដោយអ្នកជាប់ឃុំតាមរយៈកាល បង្កើតឲ្យមានមជ្ឈដ្ឋានរឹតតែមានសុវត្ថិភាព ដោយកាត់បន្ថយលទ្ធភាពនៃរបួសមុតនឹងម្ជុល ចំពោះសមាជិកសាធារណជន។ សេវាផ្តល់ដោយអ្នកជាប់ឃុំនេះ ក៏កែលំអរូបរាងនៃដងផ្លូវនិងទីកន្លែងសាធារណៈរបស់កាប្រាម៉ាតាផងដែរ។

## គំរោងការងារទីកន្លែងកាប្រាម៉ាតា

នៅខែមេសា ឆ្នាំ 1997 ក្នុងកិច្ចសហប្រតិបត្តិការជាមួយសាលាក្រុង Fairfield និងអង្គការឯទៀត ក្រសួងរបស់អភិបាលរដ្ឋបានបង្កើតគំរោងការងារទីកន្លែងកាប្រាម៉ាតា (Cabramatta Place Project) ដើម្បីដោះស្រាយការប្រើគ្រឿងញៀនខុសច្បាប់ និង ផលប៉ះពាល់របស់វាទៅលើសហគមន៍កាប្រាម៉ាតា។

គំរោងការងារទីកន្លែងកាប្រាម៉ាតា កំពុងធ្វើការប្រើវិធីសាស្ត្រប្រឆាំងគ្រឿងញៀន នៅតាមថ្នាក់តំបន់។ កិច្ចការក៏កំពុងធ្វើតទៅទៀតផងដែរលើបញ្ហាផ្សេងៗ ដូចជាអភិវឌ្ឍន៍ទេសចរណ៍ និង ការកែលំអភាពឆើតឆាយនៃតំបន់ក្រុង (ដឹកនាំដោយសាលាក្រុង Fairfield) ហើយនិងការអប់រំនិងហ្វឹកហ្វឺនការងារសំរាប់ជនវ័យក្មេង។

## ពត៌មានបន្ថែម

### ត្រូវការជំនួយឬ?

បើលោកអ្នក ឬនរណាមួយដែលលោកអ្នកស្គាល់ ត្រូវការជំនួយ ឬឱវាទដែលលាក់ការណ៍សម្ងាត់អំពីគ្រឿងញៀន សូមទូរស័ព្ទទៅកាន់សេវាកម្មពត៌មានសុរានិងគ្រឿងញៀន **(Alcohol and Drug Information Service / ADIS)** តាមទូរស័ព្ទលេខ **9361 8000** (តំបន់ក្រុងស៊ីដនីតែប៉ុណ្ណោះ) ឬទូរស័ព្ទឥតគិតថ្លៃ តាមលេខ **1800 422 599** (នៅខាងក្រៅក្រុងស៊ីដនី)។ ADIS បើកទ្វារធ្វើការគ្រប់ពេលម៉ោងទាំងអស់ ដើម្បីផ្តល់ឱវាទពត៌មាន និងការបញ្ជូនដោយលាក់ការណ៍សម្ងាត់ ទៅកាន់អង្គការទាំងពួងក្នុងតំបន់។

ក្នុងភាពជាមាតាឬបិតា ការដោះស្រាយបញ្ហាគ្រឿងញៀន អាចជាការលំបាកខ្លាំងណាស់។ ដើម្បីទទួលឱវាទអំពីរបៀបនិយាយទៅកាន់បណ្តាជនវ័យក្មេងអំពីការប្រើគ្រឿងញៀន ឬបញ្ហា ឥរិយាបថ សូមទាក់ទង **Parent Line** (ទូរស័ព្ទផ្តល់ឱវាទ សំរាប់មាតាបិតា) ដែលឥតគិតថ្លៃ តាមលេខ **13 20 55** ។

### ការរាយការណ៍អំពីឧក្រិដ្ឋកម្មគ្រឿងញៀន

ពត៌មានណាមួយដែលលោកអ្នកមាន អំពីឧក្រិដ្ឋកម្មគ្រឿងញៀន សូម្បីតែលោកអ្នកយល់ថាមិនសំខាន់ក្តី ក៏អាចជួយប៉ូលិសឲ្យធ្វើការចាប់ខ្លួនជនល្មើស។ ដើម្បីរាយការណ៍អំពីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងគ្រឿងញៀន សូមទូរស័ព្ទទៅកាន់ **Crime Stoppers** (អ្នកបញ្ឈប់ឧក្រិដ្ឋកម្ម) តាមទូរស័ព្ទឥតគិតថ្លៃ លេខ **1800 333 000** ។

### ចង់ដឹងពត៌មានបន្ថែមឬទេ?

បើលោកអ្នកចង់ដឹងពត៌មានបន្ថែមអំពីវិធានការឆ្លើយតបរបស់រដ្ឋាភិបាល NSW ទៅនឹងបញ្ហាគ្រឿងញៀន សូមបើកមើលគេហទំព័រអ៊ីនធើរណិត **www.druginfo.nsw.gov.au**